# សហគមន៍ខ្មែរកម្ពុជាក្រោម
KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ..............................ស.ខ.ក.ក.

# សេចក្តីថ្លែងការណ៍

## គាំទ្រកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស២៣ តុលា ១៩៩១

សហគមន៍ខ្មែរកម្ពុជាក្រោម ចូលរួមអបអរសាទរយ៉ាងក្លៀវក្លាខួបទី២០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិស ស្តីអំពីកម្ពុជា (២៣-១០-១៩៩១ - ២៣-១០-២០១១) និង សូមចូលរួម និងគាំទ្រយ៉ាងពេញ ទំហឹង ចំពោះបងប្អូនរួមជាតិទាំងអស់នៅជុំវិញពិភពលោក ដែលបានរួបរួមគ្នាធ្វើមហាបាតុកម្មគាំទ្រថ្ងៃ២៣ តុលាឆ្នាំ១៩៩១ និងជំរុញអោយមានការគោរពបានពេញលេញនូវកិច្ចព្រមព្រៀងនេះ។

ថ្ងៃ២៣ តុលា១៩៩១ គឺជាទិវាប្រវត្តិសាស្រ្តដ៏សំខាន់បំផុត ដែលប្រជានុរាស្រ្តខ្មែរគ្រប់រូបត្រូវតែចងចាំ និងរំលឹកជានិច្ច ព្រោះជាទិវាដែលបានបញ្ចប់សង្គ្រាមបង្ហូរឈាមរវាងខ្មែរនិងខ្មែរ បង្រួបបង្រួមជាតិ និងបញ្ចប់ការការឈ្លានពានពីបរទេស ជាពិសេសបានធានាដល់អាយុជីវិតនៃប្រទេសកម្ពុជា និងសុខមាល-ភាពនៃប្រជាជាតិខ្មែរទាំងបច្ចុប្បន្ន និងទៅអនាគត។ ព្រោះកិច្ចព្រមព្រៀមសន្តិភាពទីក្រុងបារិស២៣តុលា ១៩៩១ បានធានាដ៏ពិតប្រាកដ និងជាអន្តរជាតិនូវបូរណា-ភាពដែនដីកម្ពុជា ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស បង្កើតតុលាការឯករាជ្យ។ល។ (មិនមែនតុលាការបែបសព្វថ្ងៃនេះទេ)។

តាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិស ថ្ងៃ២៣ តុលា១៩៩១ បានតម្រូវអោយកម្ពុជារៀបចំប្រទេសឡើងវិញ តាមរបបប្រជាធិបតេយ្យសេរីពហុបក្សមួយពិតប្រាកដ នៃនិយាមអន្តរជាតិ មិនមែនសំរាប់កែលំអ តាមរបបកុម្មុយនិស្តឥណ្ឌូចិនដែលបង្កើតឡើងដោយខ្មោចយួនហោជី មិញនោះទេ។

២០ឆ្នាំបានកន្លងផុត ខ្លឹមសារនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិស មិនត្រូវបានគណបក្ស កានអំណាចអនុវត្តអោយបានត្រឹមត្រូវឡើយ មិនតែប៉ុណ្ណោះ គណបក្សកានអំណាចបានព្យាយាមលប់បំបាត់ចោល ហើយលើកដំកើងថ្ងៃ៧កមរា១៩៧៩ ដែលជាថ្ងៃយួនឈ្លានពានទៅវិញ។

បន្ទាប់ពីថ្ងៃលាត់ប្រហារ៥-៦កក្កដា១៩៩៧ គណបក្សដែលមានប្រភពដើមចេញមកពីបក្សកុម្មុយនិស្តឥណ្ឌូចិន បន្តពីបក្សប្រជាជនបដិវត្តន៍កម្ពុជារបស់ ពល ពត បានឡើងត្រួតត្រាប្រទេសកម្ពុជាទាំងស្រុង។ ចាប់ពីពេលនោះមក របតនយោបាយបានផ្លាស់ប្តូរឃ្លាតឆ្ងាយទៅៗពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិស ទៅរកការដឹកនាំប្រទេសតាមបែបកុម្មុយនិស្តផ្តាច់ការ ដ៏គួរអោយព្រួយបារម្មណ៏បំផុត។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមធ្វើការកត់សំគាល់នូវចំណុចមួយចំនួនដូចខាងក្រោម ៖

១- អំពីបូរណភាពទឹកដី

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិស ឧបសម្ពន្ធ័ទី៥ ចំណុចធំពីរ បានចែងអំពីកិច្ចព្រមព្រៀងទាក់ទីនទៅនិងអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាពនិងឯកភាពជាតិកម្ពុជា។ នៅមាត្រា១ ចំណុច១ បានចែងជាអាទ៏ថា កម្ពុជា តាមរយៈឯកសារនេះសន្យាយ៉ាងឱឡារិកថា និងថែរក្សា និងការពារអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន......។


ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៩៣៣ ០០៣
E-mail: thachsetha@gmail.com Website: http//khmerkromngo.org

ចំណុច២កថាខណ្ឌ ឃ បានចែងថា បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលមិនសមស្របទៅនិងអធិបតេយ្យ ឯករាជ្យ បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន។ នៅមាត្រា២ បានចែងថា ភាគីនានាក្នុងកិច្ចព្រមព្រៀងនេះ តាមរយៈនេះ សន្យាយ៉ាងឱឡារឹកថា ទទួលស្គាល់ និងគោរពគ្រប់បែបយ៉ាងទាំអស់ដល់ អធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិកម្ពុជា។

មាត្រា៥ បានចែងថា ក្នុងករណីមានការរំលោភ ឬការគំរាមគំហែងរំលោភលើអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឬឯកភាពជាតិកម្ពុជា ឬលើការប្តេជ្ញាចិត្តដទៃទៀតណាមួយ ក្នុងកិច្ចព្រមព្រៀងនេះ បណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ធ្វើការពិគ្រោះជាបន្ទាន់ដើម្បីអនុម័តរាលវិធានការសមស្រប ដើម្បីធានាការគោរពដល់ការប្តេជ្ញាចិត្តទាំងនោះ និងដោះស្រ័យ រាល់ការរំលោភទាំងនោះ តាមមធ្យោបាយសន្តិវិធី។

ប៉ុន្តែគណបក្សកានអំណាចបែរជាធ្វើអោយរាល់សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយដែលបានធ្វើឡើងនៅសម័យយួនត្រួតត្រា១៩៧៩-១៩៨៩ ក្លាយទៅជាស្របច្បាប់ទាំងអស់ ដែលផ្ទុយទាំស្រុងទៅនិងកិច្ចព្រមព្រៀមនេះ។ ការកំណត់ព្រំដែនប្រទេស រវាងកម្ពុជា និងវៀតណាម បានធ្វើឡើងជាទ្វេភាគី (មិនលក្ខណអន្តរជាតិ) ដែលជាហេតុនាំអោយមានការសង្ស័យ ក្នុងស្រទាប់អ្នកនយោបាយ និងមហាជនខ្មែរអំពីការបាត់បង់ទឹកដីខ្មែរ។ ការឈ្លានពានរបស់ប្រទេសថៃ ក្នុងពេលថ្មីៗ កន្លងទៅនេះ រដ្ឋាភិបាលខ្មែរបានព្រងើយកន្តើយ ដោយពុំបានលើកយកកិច្ចព្រម ព្រៀងទីក្រុងបារិសមកអនុវត្តន៍ឡើយហើយបានអូសបន្លាយពេលវេលាដ៏យូរ ធ្វើអោយបាត់បង់អាយុជីវិត ពលទាហាន ខូចខាតប្រាសាទបូរាណ ទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងថវិការជាតិយ៉ាងច្រើន។

២- អំពីប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស

ស្ថាប័ននីតិបញ្ញត្តិពុំបានបំពេញតួរនាទីរបស់ខ្លួនអោយបានពេញលេញ ជាស្ថាប័ននីតិបញ្ញត្តិក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដឡើយ ទោះបីជានៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទី ក្រុងបារិសបានតម្រូវអោយកម្ពុជាចារឹកក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេសក៏ដោយ។ តួរនាទីគណបក្សប្រឆាំងនៅក្នុងរដ្ឋសភាត្រូវបានបំភ្លេចចោល ប្រធានគណបក្សប្រឆាំងត្រូវបាន ធ្វើទុក្ខបុកម្នេញឥតឈប់ឈរ រហូតបង្ខំចិត្តនិរទេសខ្លួនទៅរស់នៅបរទេស។

អំពីសិទ្ធិមនុស្ស កិច្ចព្រមព្រៀងទីក្រុងបារិសបានចែងយ៉ាងច្បាស់អពីការសន្យារបស់កម្ពុជាក្នុងការគោរពសិទ្ធិមនុស្ស។ ឧបសម្ព័ន្ធទី៥ ចំណុច២ បានចែងជាអាទិ៍ថា ប្រវត្តិសាស្ត្រថ្មីៗប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារអោយមានវិធានការពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញ ត្រូវរួមមាន សេចក្តីថ្លែងការណ៍មួយអំពីសិទ្ធិជាមូលដ្ឋាន ក្នុងនោះមានសិទ្ធិក្នុងការមានជីវិតរស់នៅសេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំ និងបង្កើតសមាគម រួមមានគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំអោយមានការដកហូតកម្មសិទ្ធិដោយវិធីផ្តាច់ការ ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជម្ងឺចិត្តដ៏ត្រឹមត្រូវ...... ។ សិទ្ធិមនុស្សទាំងអស់ដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងបារិស ត្រូវបានរាជរដ្ឋាភិបាលសព្វ ថ្ងៃរំលោភស្ទើតែទាំងស្រុង ដូចជាការជួបប្រជុំសំដែងមតិការធ្វើបាតុកម្ម ការប្រារព្ធពីធីធំៗតាមបែប សាសនានៅទីសាធារណៈ។ល។ត្រូវបានហាមឃាត់។

សហគមន៍ខ្មែរកម្ពុជាក្រោម
THE KHMER KAMPUCHEA KROM COMMUNITY

៣- អំពីតុលាការឯករាជ្យ

ឧបសម្ព័ន្ធទី៥ ចំណុច៥ ចែងថា ត្រូវបង្កើតតុលាការមួយឯករាជ្យ ដែលត្រូវមានអំណាចដាក់អោយអនុវត្តនូវបណ្តាសិទ្ធិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

តុលាការបច្ចុប្បន្ន មិនមែនជាតុលាការដែលបានបង្កើតឡើង តាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងបារិសនោះទេ គឺជាតុលាការកុម្មុយនិស្តដែលបានរក្សាទុកតាំងពីឆ្នាំ១៩៧៩រហូតមក។

ក្នុងខួបគំរប់ទី២០ឆ្នាំ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិសនេះ សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវយ៉ាងទទូចដល់បណ្តាប្រទេសដែលជាហត្ថលេខី មេត្តាពិនិត្យឡើងវិញ នូវរាល់ការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារិស របស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន និងចាត់វិធានការជាបន្ទាន់ ដើម្បីតម្រង់ទិសរាជរដ្ឋាភិបាលអោយអនុវត្តបានត្រឹមត្រូវទៅតាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងបារិសដ៏មានសារៈសំខាន់នេះ ដោយការទទួលខុសត្រូវខ្ពស់។

ភ្នំពេញ, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១១

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

អតីតសមាជិកព្រឹទ្ធសភា